ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
National Region King

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

Ministry of Industry, Mines and Energy

លេខៈ ៤៧១ ឧរថ.បល.ប្រក

# ប្រកាស
# ស្តីពី
# ការរៀបចំ និង ការប្រព្រឹត្តទៅ របស់មជ្ឈមណ្ឌលផលិតភាព

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការដំឡើងផលិតភាពអង្គភាពទៅជាមជ្ឈមណ្ឌលផលិតភាពជាតិ នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល។
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង។

# សម្រេច

**ប្រការ ១.–**

មជ្ឈមណ្ឌលផលិតភាពជាតិជាអង្គភាពសេនាធិការឱ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលលើការងារ ផលិតភាព ស្ថិតនៅក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្ម មានតួនាទី និងភារកិច្ចដូចតទៅ:

- បំពេញភារកិច្ច និងអនុវត្តកាតព្វកិច្ចនៃសមាជិកអង្គការផលិតភាពអាស៊ី ។
- ទំនាក់ទំនងសហប្រតិបត្តិការជាមួយអង្គការផលិតភាពនៃប្រទេសនានា ។
- គ្រប់គ្រង សម្របសម្រួល និងជំរុញចលនាផលិតភាពនៅព្រះរាជាណាចក្រកម្ពុជា ។
- រៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាក្នុងទិសដៅអភិវឌ្ឍវិស័យផលិតភាព សម្រាប់សេដ្ឋកិច្ច សង្គមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។
- ផ្តល់យោបល់អំពីគោលនយោបាយ កម្មវិធីលើកកម្ពស់ផលិតភាពគុណភាព និងប្រសិទ្ធភាពការងារសម្រាប់ សកម្មភាពថ្នាក់ជាតិ ។
- ផ្តល់យោបល់អំពីគោលដៅផលិតភាពជាតិ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ជាតិ ។
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងវិស័យឯកជន ដើម្បីជំរុញលើកកម្ពស់ការងារផលិតភាព ។
- រៀបចំបង្កើត និងលើកសំណើអំពីនីតិវិធីបទដ្ឋាន នៃទស្សនៈផលិតភាពទៅតាមនិន្នាការកម្រិតអភិវឌ្ឍនៃ ស្ថានភាពសេដ្ឋកិច្ច-សង្គម ។
- ធ្វើការផ្តល់សេវាកម្ម ពិគ្រោះយោបល់ និងបណ្តុះបណ្តាលលើផ្នែកផលិតភាព ។
- ជំរុញ និងគាំទ្រការបង្កើតសហគ្រាសពិគ្រោះយោបល់លើផ្នែកគ្រប់គ្រងផលិតភាពផលិតកម្ម និងសេវាកម្ម ។
- រៀបចំជំរុញការងារផ្គូផ្គងកម្រិតផលិតភាពរបស់សហគ្រាសឯកជន ដើម្បីបង្កើនល្បឿនលើកកម្ពស់ផលិត ភាព ។
- ធ្វើការអភិវឌ្ឍន៍ផលិតភាព និងគុណភាព ជាពិសេសវប្បធម៌ផលិតភាព ដើម្បីលើកកម្ពស់សមត្ថភាពប្រកួត ប្រជែង ។
- សហការជាមួយអង្គការជាតិ និងអន្តរជាតិ ដើម្បីរៀបចំ និងអនុវត្តគម្រោងជំរុញការអភិវឌ្ឍន៍ផលិតភាព ជាតិ ។
- សហការជាមួយអង្គការផលិតភាពអាស៊ី ដើម្បីផ្តល់ការលើកទឹកចិត្តដល់អង្គភាព ឬ អ្នកមានស្នាដៃលើការ ងារផលិតភាពនៅកម្ពុជា ។
- ធ្វើជាសេនាធិការរបស់ក្រុមប្រឹក្សាផលិតភាពជាតិ ។
- សិក្សា ស្រាវជ្រាវ ចងក្រង រៀបចំស្ថិតិ សន្ទស្សន៍ផលិតភាព និងផ្សព្វផ្សាយឯកសារព័ត៌មានអំពីផលិតភាព ។

**ប្រការ២.–**

មជ្ឈមណ្ឌលផលិតភាពជាតិ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**ប្រការ៣.–**

មជ្ឈមណ្ឌលផលិតភាពជាតិ មានរចនាសម្ព័ន្ធដូចតទៅ:

១- លេខាធិការដ្ឋាន

២- ការិយាល័យជំរុញផលិតភាព

៣- ការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍

៤- ការិយាល័យពិគ្រោះយោបល់ និងបណ្ដុះបណ្ដាល

៥- ការិយាល័យ ទិន្នន័យ និងព័ត៌មានផលិតភាព

លេខាធិការដ្ឋាន និងការិយាល័យនិមួយៗ ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

**ប្រការ៤.–**

អំពីតួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាន និងការិយាល័យនិមួយៗមានដូចតទៅ:

**១- លេខាធិការដ្ឋាន**

**<u>តួនាទី:</u>**

លេខាធិការដ្ឋានជាសេនាធិការឱ្យថ្នាក់ដឹកនាំមជ្ឈមណ្ឌលផលិតភាពជាតិ លើការងារគ្រប់គ្រងរដ្ឋបាល លិខិតស្នាម ឯកសារ និងបុគ្គលិកមជ្ឈមណ្ឌលផលិតភាពជាតិ។

**<u>ភារកិច្ច:</u>**

- គ្រប់គ្រងមន្ត្រីរាជការ ក្នុងមជ្ឈមណ្ឌលផលិតភាពជាតិ។
- គ្រប់គ្រង និងចងក្រងលិខិតចេញ-ចូលគ្រប់ប្រភេទក្នុងមជ្ឈមណ្ឌលផលិតភាពជាតិ។
- បែងចែង និងបញ្ជូនលិខិត ឯកសារគ្រប់ប្រភេទក្នុងមជ្ឈមណ្ឌលផលិតភាពជាតិ។
- ព្រាង និងសម្របសម្រួលរាល់លិខិតរបស់មជ្ឈមណ្ឌលលើការងាររដ្ឋបាល។
- គ្រប់គ្រង ផ្គត់ផ្គង់ បែងចែងសម្ភារៈការិយាល័យក្នុងមជ្ឈមណ្ឌល។
- លើកគម្រោងចំណាយរដ្ឋបាល និងគម្រោងចំណាយការងារសហប្រតិបត្តិការប្រចាំឆ្នាំរបស់មជ្ឈមណ្ឌល។
- សម្របសម្រួលការងារ ជាមួយការិយាល័យ ក្នុងមជ្ឈមណ្ឌលផលិតភាពជាតិ។
- គ្រប់គ្រងឯកសារចលនទ្រព្យ និងអចលនទ្រព្យរបស់មជ្ឈមណ្ឌលផលិតភាពជាតិ។
- បូកសរុប និងធ្វើរបាយការណ៍រាល់សកម្មភាពរបស់មជ្ឈមណ្ឌល ជូនថ្នាក់ដឹកនាំ អគ្គនាយក និងជូនក្រសួងតាមពេលវេលាកំណត់។
- រៀបចំពិធីការក្នុងការទទួលភ្ញៀវ សិក្ខាសាលា វគ្គបណ្ដុះបណ្ដាល កិច្ចប្រជុំ និងពិធីផ្សេងៗពាក់ព័ន្ធនឹងការងារមជ្ឈមណ្ឌលផលិតភាពជាតិ។

- ផ្តល់មតិលើការជ្រើសរើសបេក្ខជន ទៅចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលថ្នាក់ជាតិ និងអន្តរជាតិនានា។

## ២- ការិយាល័យជំរុញផលិតភាព

**<u>តួនាទីៈ</u>**

ការិយាល័យជំរុញផលិតភាព ជាសេនាធិការឱ្យថ្នាក់ដឹកនាំមជ្ឈមណ្ឌល លើការងារផលិតភាព។

**<u>ភារកិច្ចៈ</u>**

- ផ្សព្វផ្សាយសាធារណៈអំពីចលនាផលិតភាព តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងៗ។
- បង្កើត និងពង្រឹងភាពជាដៃគូរជាមួយអង្គភាព សហគ្រាស នៃវិស័យឯកជន ទាំងថ្នាក់ជាតិ និង អន្តរជាតិ ក្នុងក្របខ័ណ្ឌលើកកម្ពស់ផលិតភាព និងគុណភាព។
- សម្របសម្រួលក្នុងការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចប្រជុំទាំងថ្នាក់ជាតិ និងអន្តរជាតិនានា
- សហការជាមួយអង្គការផលិតភាពអាស៊ី (APO) ដើម្បីផ្តល់ជារង្វាន់លើកទឹកចិត្តដល់អង្គភាព សហគ្រាសនានាដែលមានស្នាដៃល្អក្នុងការលើកកម្ពស់ផលិតភាព និងគុណភាព ។
- ផ្សព្វផ្សាយនូវរបកគំហើញ នៃការស្រាវជ្រាវអំពីផលិតភាព និងគុណភាព ។
- លើកសំណើទៅអង្គការផលិតភាពអាស៊ី (APO) និងស្ថាប័នអន្តរជាតិនានា ដើម្បីអនុវត្តគម្រោង ព្រម ទាំងជំរុញការផលិតភាព ។

## ៣- ការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍

**<u>តួនាទីៈ</u>**

ការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍជាសេនាធិការឱ្យថ្នាក់ដឹកនាំមជ្ឈមណ្ឌល លើការងារស្រាវជ្រាវ និង អភិវឌ្ឍ។

**<u>ភារកិច្ចៈ</u>**

- រៀបចំលើកគោលនយោបាយ និងផែនការសកម្មភាពនានាដែលទាក់ទងទៅនឹងចលនាផលិតភាព ក្នុងទិសដៅស្របតាមគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់រាជរដ្ឋាភិបាល ។
- ធ្វើការស្រាវជ្រាវពីតម្រូវការសម្រាប់ការបណ្តុះបណ្តាល ក្នុងក្របខ័ណ្ឌលើកកម្ពស់ផលិតភាពរបស់អង្គ ភាព និងសហគ្រាសនានា លើគ្រប់វិស័យទូទាំងប្រទេស ។
- រៀបចំផែនការ និងយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ប្រសិទ្ធភាពការងាររបស់មជ្ឈមណ្ឌល និងពង្រឹង សមត្ថភាពមន្ត្រីជំនាញ ។
- សិក្សាស្រាវជ្រាវពីទស្សនទានផលិតភាព និងគុណភាព ដើម្បីទុកជាឯកសារសម្រាប់ទ្រទ្រង់សកម្មភាព ការងាររបស់ការិយាល័យពិគ្រោះយោបល់ និងបណ្តុះបណ្តាល ។
- រៀបចំបកប្រែឯកសារ និងបោះពុម្ពសៀវភៅអំពីទស្សនទាន ផលិតភាព និងគុណភាព ។
- ធ្វើផែនការអភិវឌ្ឍន៍ផលិតភាព ដើម្បីជំរុញប្រពៃណីលើកកម្ពស់ផលិតភាព ក្នុងការអភិវឌ្ឍន៍វប្បធម៌ ផលិតភាព ។

- រៀបចំចងក្រងស្ថិតិ សន្ទស្សន៍ផលិតភាព និងព័ត៌មានផលិតភាព ។
- លើកគម្រោងសហប្រតិបត្តិការ ជាមួយស្ថាប័ននានាតាមការចាំបាច់ ដើម្បីអភិវឌ្ឍផលិតភាព សម្រាប់សេដ្ឋកិច្ច និងសង្គម ។

**៤- ការិយាល័យពិគ្រោះយោបល់ និងបណ្តុះបណ្តាល**

**<u>តួនាទី:</u>**

ការិយាល័យពិគ្រោះយោបល់ និងបណ្តុះបណ្តាល ជាសេនាធិការឱ្យថ្នាក់ដឹកនាំមជ្ឈមណ្ឌលលើការងារពិគ្រោះយោបល់ និងបណ្តុះបណ្តាលបច្ចេកទេសគ្រប់មុខជំនាញ ។

**<u>ភារកិច្ច:</u>**

- ធ្វើការផ្តល់សេវាកម្មបណ្តុះបណ្តាល និងពិគ្រោះយោបល់អំពីការលើកកម្ពស់ផលិតភាពគុណភាពដល់អង្គភាព សហគ្រាសនានា ។
- រៀបចំកម្មវិធីសម្រាប់ការសម្រាប់ការបណ្តុះបណ្តាលផ្នែកផលិតភាពដល់អង្គភាព និងសហគ្រាសនានា ។
- ផ្តល់យោបល់អំពីគោលនយោបាយ និងកម្មវិធីលើកកម្ពស់ផលិតភាព គុណភាព និងប្រសិទ្ធភាពការងារសម្រាប់សកម្មភាពថ្នាក់ជាតិ ។
- ជំរុញការងារផ្គូផ្គងកម្រិតផលិតភាពរបស់ស្ថាប័ន និងសហគ្រាស ដើម្បីបង្កើនល្បឿនលើកកម្ពស់ ផលិតភាព និងគុណភាព ។
- សហប្រតិបត្តិការ ទំនាក់ទំនងជាមួយអង្គការផលិតភាពអាស៊ី និងអង្គការផលិតភាពជាតិដទៃទៀត ដើម្បីទទួលយកបទពិសោធន៍ និងវិធីសាស្ត្រថ្មីៗ សម្រាប់លើកកម្ពស់សេវាកម្មបណ្តុះបណ្តាល និងពិគ្រោះយោបល់ ។
- សហការសម្របសម្រួលការងារជាមួយជំនាញការខាងផ្នែកពិគ្រោះយោបល់នានា ដែលអង្គការផលិតភាពអាស៊ីបញ្ជូនមកកម្ពុជា ដើម្បីពង្រឹងសមត្ថភាព និងលើកកម្ពស់គុណភាព សេវាកម្មផ្តល់យោបល់ ។
- លើកសំណើទៅអង្គការផលិតភាពអាស៊ី និងស្ថាប័នអន្តរជាតិនានា ដើម្បីអនុវត្តគម្រោង ព្រមទាំងរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីផលិតភាព និងគុណភាព ការធ្វើកម្មសិក្សានានានៅក្នុង និងក្រៅប្រទេស ។

**៥- ការិយាល័យទិន្នន័យ និងព័ត៌មានផលិតភាព**

**<u>តួនាទី:</u>**

ការិយាល័យទិន្នន័យ និងព័ត៌មានផលិតភាព ជាសេនាធិការឱ្យថ្នាក់ដឹកនាំមជ្ឈមណ្ឌលលើការងារប្រមូលចងក្រងទិន្នន័យ និងព័ត៌មានផ្សេងៗ នៃសកម្មភាពផលិតភាព ។

**<u>ភារកិច្ច:</u>**

- រៀបចំ និងចងក្រងស្ថិតិ សន្ទស្សន៍ផលិតភាព និងព័ត៌មានផលិតភាព ។
- ផ្សព្វផ្សាយជាសាធារណៈអំពីចលនាផលិតភាព តាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងៗ ។

- គ្រប់គ្រងស្ថានីយព័ត៌មាន គ្រប់គ្រងកុំព្យូទ័រ គ្រប់គ្រងគេហទំព័រ និងសហការណ៍ជាមួយលេខាធិការដ្ឋាន និងការិយាល័យនៃមជ្ឈមណ្ឌលផលិតភាពជាតិ ដើម្បីទទួល ឬផ្តល់ព័ត៌មានសម្រាប់ដំណើរការរបស់មជ្ឈមណ្ឌលផលិតភាពជាតិ ។
- រៀបចំការងារសហប្រតិបត្តិការ កិច្ចការផលិតភាព ជាមួយបណ្តាអង្គភាព ។
- ប្រមូលព័ត៌មានដែលទាក់ទងនឹងការងារផលិតភាព តាមរយៈប្រព័ន្ធព័ត៌មានវិទ្យា និងវិធីផ្សេងៗទៀត ។
- ចងក្រងទិន្នន័យសម្រាប់បម្រើឱ្យវិស័យផលិតភាព ។
- សហការរៀបចំការងារ E-Learning តាមប្រព័ន្ធអេឡិចត្រូនិចជាមួយការិយាល័យពាក់ព័ន្ធ ។

**ប្រការ៥.**–

បទប្បញ្ញត្តិ និងសេចក្តីសម្រេចទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.**–

អគ្គនាយកនៃនាយកដ្ឋានឧស្សាហកម្ម អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងប្រធានមជ្ឈមណ្ឌលផលិតភាពជាតិ មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ចរៀងៗខ្លួនតាមប្រកាសនេះ ។

**ប្រការ៧.**–

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៨

ហត្ថលេខា និងត្រា

**ស៊ុយ សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់នាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- គ្រប់នាយកដ្ឋានសេនាធិការក្រសួង
- គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង

“ដើម្បីជ្រាបជាព័ត៌មាន ”

- ដូចប្រការ ៦ “ដើម្បីអនុវត្ត ”
- ឯកសារ–កាលប្បវត្តិ

# រចនាសម្ព័ន្ធមជ្ឈមណ្ឌលផលិតភាពជាត

តារាងឧបសម្ព័ន្ធនៃប្រកាសលេខ ៤៧១ ឧរថ.បល.ប្រក
ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៨




បានឃើញ

ភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៨

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

**ស៊ុយ សែម**

បានឃើញ

ភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៨

**អគ្គនាយកដ្ឋានឧស្សាហកម្ម**

**ម៉េង សក្តិធារ៉ា**

ភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៨

**ប្រធានមជ្ឈមណ្ឌលផលិតភាពជាតិ**

**យ៉ា ប៊ុន ណា**